**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៣-១៥ ខែវិច្ឆិកា ឆ្នាំ ២០១៨ នៅប្រទេសសិង្ហបុរី

* * * * *

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលបានប្រព្រឹត្តទៅក្រោមមូលបទ «ភាពរឹងមាំ និងនវានុវត្តន៍របស់អាស៊ាន» នៅថ្ងៃទី ១៣-១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី។

លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំកំពូល មានដូចខាងក្រោម៖

**កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣ / អាហារការងារពេលល្ងាចសម្រាប់ថ្នាក់ដឹកនាំអាស៊ាន៖**

ថ្នាក់ដឹកនាំអាស៊ានបានពិភាក្សាប្រកបដោយផ្លែផ្កា និងបានកត់សម្គាល់នូវវឌ្ឍនភាពក្នុងការកសាងសហគមន៍អាស៊ានដែលរឹងមាំ និងមាននវានុវត្តន៍ និងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យកាន់តែស៊ីជម្រៅថែមទៀតនូវទំនាក់ទំនងអាស៊ានជាមួយពិភពលោក។ ថ្នាក់ដឹកនាំបានអះអាងជាថ្មីនូវការប្តេជ្ញារួមគ្នាក្នុងការអនុវត្តដោយពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៃចក្ខុវិស័យសហគមន៍អាស៊ាន២០២៥ និងចក្ខុវិស័យរបស់ថ្នាក់ដឹកនាំអាស៊ានសម្រាប់អាស៊ានដែលរឹងមាំ និងមាននវានុវត្តន៍។

ថ្នាក់ដឹកនាំបានគូសបញ្ជាក់អំពីសារសំខាន់ក្នុងការពង្រឹងមជ្ឈភាព និងឯកភាពអាស៊ាន នៅក្នុងការប្រឹងប្រែងកសាងសហគមន៍ និងការធ្វើឲ្យកាន់តែជិតស្និទ្ធជាមួយដៃគូខាងក្រៅអាស៊ាន។ ថ្នាក់ដឹកនាំបានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាឆ្ពោះទៅរកនិម្មាបនកម្មតំបន់ដែលផ្អែកលើច្បាប់ បើកចំហ មានតម្លាភាព និងបរិយាប័ន្ន និងដោយប្រកាន់ខ្ជាប់យន្តការនានាដែលដឹកនាំដោយអាស៊ាន។

ថ្នាក់ដឹកនាំក៏បានផ្លាស់ប្តូរយោបល់ទៅលើបញ្ហាសំខាន់ៗជាច្រើនរួមមាន ការតភ្ជាប់ ការកាត់បន្ថយគម្លាតអភិវឌ្ឍ បណ្តាញទីក្រុងឆ្លាតអាស៊ាន បដិវត្តឌីជីថល និងបញ្ហាផ្សេងៗទៀតដែលជាការកង្វល់រួមដែលប៉ះពាល់ដល់តំបន់ និងពិភពលោក។

លើទិដ្ឋភាពសេដ្ឋកិច្ច ថ្នាក់ដឹកនាំបានកត់សម្គាល់ដោយការពេញចិត្តដែលតំបន់សម្រេចបាន GDP រួមគ្នា ២.៨ ទ្រីលាន នៅក្នុងឆ្នាំ២០១៧ និងបានកត់សម្គាល់កំណើនដែលរំពឹងថានឹងរក្សាស្ថិរភាព ក្នុងអត្រា ៥.១ ភាគរយ និង៥.២ ភាគរយ នៅក្នុងឆ្នាំ២០១៨ និង២០១៩។ ថ្នាក់ដឹកនាំបានស្វាគមន៍វឌ្ឍនភាពដែល



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

សម្រេចបានប្រកបដោយខ្លឹមសារនៅក្នុងការចរចារភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) ក្នុងឆ្នាំ ២០១៨ និងបានប្តេជ្ញាសារជាថ្មីក្នុងការបញ្ចប់ RCEP ដែលទំនើប គ្រប់ជ្រុងជ្រោយ មានគុណភាពខ្ពស់ និង ផ្តល់ផលប្រយោជន៍ទៅវិញទៅមក នៅក្នុងឆ្នាំ២០១៩។

សម្រាប់ផ្នែកសង្គម-វប្បធម៌ ថ្នាក់ដឹកនាំបានរិះរកដំណោះស្រាយរួមគ្នាក្នុងការធ្វើឲ្យស៊ីជម្រៅ ការស្គាល់អត្តសញ្ញាណអាស៊ាន និងអាស៊ានរួម និងបានស្វែងរកមធ្យោបាយប្រកបដោយនវានុវត្តន៍ ក្នុងការផ្តល់ ឲ្យប្រជាជននូវជំនាញ និងសមត្ថភាព ដែលអាចជួយឲ្យអាស៊ាននៅតែរក្សាបាននូវភាពរស់រវើក បរិយាប័ន្ន និង ជាកន្លែងដែលប្រកបដោយថាមវន្តសម្រាប់ប្រជាជនរស់នៅ ធ្វើការងារ និងកំសាន្ត។

ថ្នាក់ដឹកនាំបានត្រៀមជាស្រេចដើម្បីផ្តល់ជំនួយដល់ប្រទេសមីយ៉ាន់ម៉ា ក្នុងការរៀបចំការធ្វើមាតុភូមិ និវត្តន៍របស់ប្រជាជនមកប្រទេសមីយ៉ាន់ម៉ាវិញ ក្នុងស្មារតីសាមគ្គីភាពជាគ្រួសារតែមួយ និងបានគូសបញ្ជាក់ អំពីតម្រូវការក្នុងការកសាងនូវជំនឿ និងទំនុកចិត្តរវាងជនធ្វើមាតុភូមិនិវត្តន៍ និងប្រជាជននៅក្នុងសហគមន៍ ក៏ដូចជារវាងមីយ៉ាន់ម៉ា និងសហគមន៍អន្តរជាតិ។ ថ្នាក់ដឹកនាំក៏បានស្នើសុំប្រទេសមីយ៉ាន់ម៉ាឲ្យអញ្ជើញក្រុម ការងារនៃមជ្ឈមណ្ឌលអាស៊ានសម្រាប់សម្របសម្រួលជំនួយមនុស្សធម៌ មកបំពេញទស្សនកិច្ចនៅប្រទេស មីយ៉ាន់ម៉ា ដើម្បីវាយតម្លៃអំពីស្ថានការណ៍។

នៅក្នុងកិច្ចប្រជុំកំពូល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់យ៉ាងច្បាស់លាស់ទៅលើចំណុច សំខាន់ៗ ដូចខាងក្រោម៖

- ស្នើឲ្យគ្រប់ភាគីពាក់ព័ន្ធបន្តការពិភាក្សាស្តីពីការអនុវត្តក្របខ័ណ្ឌទីក្រុងឆ្លាត ឆ្នាំ២០១៨ និងរិះរក មធ្យោបាយដើម្បីធ្វើសមាហរណកម្ម និងធ្វើសុខដុមនីយកម្មផែនការមេស្តីពីការអភិវឌ្ឍទីក្រុង ឆ្លាតរបស់ខ្លួន ទៅក្នុងយន្តការតំបន់រួមមួយ ដែលអាចសម្របសម្រួល និងគ្រប់គ្រងប្រកបដោយ តុល្យភាព។
- គូសបញ្ជាក់អំពីសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងអន់គុណភាព ក្នុង តំបន់ និងបានស្នើឲ្យព្រះរាជាណាចក្រថៃ ដែលជាប្រធានអាស៊ាន ឆ្នាំ២០១៩ ដាក់បញ្ហានេះ ទៅជារបៀបវារៈចម្បងរបស់កិច្ចប្រជុំកំពូលអាស៊ានលើកក្រោយ។
- ក្នុងបរិបទទំនាក់ទំនងក្រៅតំបន់របស់អាស៊ាន **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងបញ្ជាក់ថា កម្ពុជាស្វាគមន៍រាល់គំនិតផ្តួចផ្តើមទាំងឡាយណា ដែលផ្តល់ផលប្រយោជន៍ដល់ការតភ្ជាប់តំបន់ ការពង្រឹងសាមគ្គីភាព និងមជ្ឈភាពរបស់អាស៊ាន ព្រមទាំងមានលក្ខណៈបើកចំហ បរិយាប័ន្ន និងបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។

កិច្ចប្រជុំកំពូលបានអនុម័តឯកសារសំខាន់ៗចំនួន៧ រួមមាន ១) ក្របខ័ណ្ឌទីក្រុងឆ្លាតអាស៊ាន ២) សេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍ណែនាំស្តីពីជំនួយផ្នែកកុងស៊ុល ដោយស្ថានបេសកកម្មការទូតនានា នៃបណ្តាប្រទេសសមាជិកអាស៊ាន នៅក្នុងបណ្តាប្រទេសទីបី ដល់ជនជាតិនៃប្រទេសសមាជិកអាស៊ានដទៃ ទៀត ៣) ផែនការមេសម្រាប់ការជំរុញអាស៊ាន២០២៥: ការបញ្ជ្រាបចំណេះដឹងសិទ្ធជនពិការ ៤) សេចក្តីថ្លែង ការណ៍អាស៊ានស្តីពីការអនុម័តទិវាយុវជនអាស៊ាន ក្នុងសកម្មភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និង គ្រោះមហន្តរាយ ៥) សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការលើកកម្ពស់ការងារបៃតង សម្រាប់កំណើន ប្រកបដោយបរិយាប័ន្ន និងសមធម៌ក្នុងសហគមន៍អាស៊ាន ៦) សេចក្តីប្រកាសរួមអាស៊ានស្តីពីការប្រែប្រួល អាកាសធាតុជូនសន្និសីទលើកទី២៤ នៃភាគីពាក់ព័ន្ធ (COP 24) ចំពោះអនុសញ្ញាក្របខ័ណ្ឌអង្គការ សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និង ៧) សេចក្តីប្រកាសរួមអាស៊ានជូនកិច្ចប្រជុំ លើកទី១៤ នៃសន្និសីទរបស់ភាគីអនុសញ្ញាស្តីពីពិពិធភាពជីវៈចម្រុះ (CBD COP 14)។

**កិច្ចប្រជុំជាមួយក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ាន៖**

មុនពេលអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣ **សម្តេចតេជោនាយករដ្ឋមន្ត្រី** រួមជាមួយថ្នាក់ដឹកនាំអាស៊ានផ្សេងទៀត បានអញ្ជើញចូលរួមស្តាប់បទបង្ហាញដោយក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ាន។ **សម្តេចតេជោ** បានបញ្ជាក់ពីភាពចាំបាច់ក្នុងការបង្កើតវេទិកាពិគ្រោះយោបល់រដ្ឋ-ឯកជនសម្រាប់សុខដុមនីយកម្មទូលំទូលាយនៃយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលជាតិ ដោយស្នើឲ្យក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ាន ចាត់ទុកបញ្ហានេះជាកិច្ចការអាទិភាពសំខាន់ចាំបាច់។ **សម្តេចតេជោ** បានធ្វើចំណាប់អារម្មណ៍ថា នៅពេលដែលកិច្ចប្រឹងប្រែងនេះសម្រេចបាន វានឹងធ្វើឲ្យប្រទេសនីមួយៗត្រៀមខ្លួនបានគ្រប់លក្ខណៈ ក្នុងការចាប់យកឱកាសពីបដិវត្តន៍ឧស្សាហកម្មទី៤ ក៏ដូចជាប្រែក្លាយតំបន់អាស៊ាន ទៅជាតំបន់ដែលមានប្រកួតប្រជែងខ្ពស់ និងនាំមុខគេក្នុងវិស័យសេដ្ឋកិច្ចឌីជីថល។

**កិច្ចប្រជុំកំពូលក្រៅផ្លូវការអាស៊ាន-អូស្ត្រាលី អមដោយអាហារពេលព្រឹក**

ថ្នាក់ដឹកនាំអាស៊ាន និងអូស្ត្រាលី បានស្វាគមន៍ការរៀបចំដោយជោគជ័យកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី នៅទីក្រុងស៊ីដនី កាលពីខែមិនា ឆ្នាំ២០១៨ កន្លងមក និងបានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តចំពោះសេចក្តីថ្លែងការណ៍ទីក្រុងស៊ីដនី។

ថ្នាក់ដឹកនាំក៏បានប្តេជ្ញាថានឹងធ្វើឲ្យស៊ីជម្រៅថែមទៀតនូវទំនាក់ទំនងអាស៊ាន-អូស្ត្រាលី និងជំរុញសេដ្ឋកិច្ចដែលបើកចំហរ ប្រកបដោយថាមពល និងដែលអាចប្រកួតប្រជែងបាន សម្រាប់ជាប្រយោជន៍រួមរបស់តំបន់។ ថ្នាក់ដឹកនាំបានប្តេជ្ញាក្នុងការបង្កើនពាណិជ្ជកម្ម តាមរយៈកិច្ចខិតខំប្រឹងប្រែងសហប្រតិបត្តិការលើការវិនិយោគ ដើម្បីធ្វើឲ្យមានកំណើនការភ្ជាប់ទំនាក់ទំនងប្រជាជន និងប្រជាជន និងជំរុញឲ្យមានកិច្ចសហប្រតិបត្តិការច្រើនថែមទៀតនៅក្នុងគំនិតផ្តួចផ្តើមសម្រាប់កសាងសមត្ថភាព ដែលផ្តោតជាសំខាន់ទៅលើការអប់រំ និងកម្មវិធីផ្លាស់ប្តូរកីឡា។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះការពង្រីកផែនការកូឡំបូថ្មីរបស់អូស្ត្រាលីដល់បណ្តាប្រទេសសមាជិកអាស៊ានទាំងអស់ ដើម្បីលើកកម្ពស់ថែមទៀតនូវការតភ្ជាប់រវាងប្រជាជននិងប្រជាជនឲ្យកាន់តែទូលំទូលាយ តាមរយៈការជួយគាំទ្រដល់សិស្ស-និស្សិតអូស្ត្រាលីមកសិក្សា និងអនុវត្តការងារនៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។

**កិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី២១**

ថ្នាក់ដឹកនាំបានស្វាគមន៍ការប្រារព្ធពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី១៥ នៃភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន និងបានវាយតម្លៃខ្ពស់ចំពោះការរៀបចំសកម្មភាពផ្សេងៗដោយជោគជ័យ ដើម្បីរំលឹកឆ្នាំអាស៊ាន-ចិននៃនវានុវត្តន៍ ឆ្នាំ២០១៨។ ថ្នាក់ដឹកនាំបានធ្វើការកត់សម្គាល់ដោយសោមនស្សរីករាយថា ចិននៅតែជាដៃគូពាណិជ្ជកម្មធំជាងគេបង្អស់របស់អាស៊ាន ដែលមានការផ្លាស់ប្តូរពាណិជ្ជកម្មក្នុងទំហំទឹកប្រាក់ ៤៤១.៦ប៊ីលានដុល្លារអាមេរិក។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រកាសគាំទ្រសេចក្តីថ្លែងការណ៍ស្តីពីចក្ខុវិស័យភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ឆ្នាំ២០៣០ និងបានសង្កត់ធ្ងន់អំពីតម្រូវការក្នុងការជំរុញថែមទៀតការយល់ដឹងអំពីទំនាក់ទំនងអាស៊ាន-ចិនលើគ្រប់វិស័យ ដើម្បីរួមចំណែកដល់ការកសាងជំនឿ និងទំនុកចិត្ត ដែលជាស្ពានមិត្តភាពរវាងប្រជាជននិងប្រជាជន។ សម្តេចតេជោ ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរិះរករួមបញ្ចូលគ្នា និងការបំពេញឲ្យគ្នាទៅវិញទៅមករវាងគំនិតផ្តួចផ្តើមនៃផែនការមេស្តីពីការតភ្ជាប់អាស៊ាន និងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយនិងវិថីមួយរបស់ចិន ។

កិច្ចប្រជុំកំពូលបានស្វាគមន៍ការកំណត់យកឆ្នាំ២០១៩ជាឆ្នាំផ្លាស់ប្តូរសារព័ត៌មានអាស៊ាន-ចិន ហើយកិច្ចប្រជុំកំពូលក៏បានអនុម័តសេចក្តីថ្លែងការណ៍ចក្ខុវិស័យភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ឆ្នាំ២០៣០ ដែលបង្ហាញពីការប្តេជ្ញារួមក្នុងការលើកកម្ពស់ទំនាក់ទំនងឈានខ្ពស់ឡើងមួយកម្រិតទៀត។

**កិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េ លើកទី២០**

ថ្នាក់ដឹកនាំអាស៊ានបានវាយតម្លៃខ្ពស់ចំពោះគោលនយោបាយទិសខាងត្បូងថ្មីរបស់សាធារណរដ្ឋកូរ៉េ និងបានបញ្ជាក់សារជាថ្មីអំពីការគាំទ្រសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការវប្បធម៌ និងទំនាក់ទំនងប្រជាជននិងប្រជាជនឲ្យកាន់តែជិតស្និទ្ធ ដែលទាំងនេះគឺជាផ្នែកនៃសសរស្តម្ភទាំងបីនៃកិច្ចសហប្រតិបត្តិការអាស៊ាន-សាធារណរដ្ឋកូរ៉េ។

ពាក់ព័ន្ធនឹងបញ្ហាឧបទ្វីបកូរ៉េ ថ្នាក់ដឹកនាំបានស្វាគមន៍ជំនួបកំពូលអន្តរកូរ៉េទាំងបីលើក ដែលបានរៀបចំឡើងនៅក្នុងឆ្នាំនេះ និងជំនួបកំពូលអាមេរិក-ស.ប.ប.កូរ៉េ នៅប្រទេសសិង្ហបុរី កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨។ ថ្នាក់ដឹកនាំអាស៊ានបានទទួលស្គាល់ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រធានាធិបតីម៉ូន ដែលបាននាំមកនូវវឌ្ឍនភាពទាំងនេះ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្វាគមន៍នូវបំណងតម្លើងកិច្ចប្រជុំមេគង្គ-សាធារណរដ្ឋកូរ៉េ ទៅជាកម្រិតកិច្ចប្រជុំកំពូល។ **សម្តេចតេជោ** ក៏បានស្វាគមន៍គោលនយោបាយទិសខាងត្បូងថ្មីរបស់សាធារណរដ្ឋកូរ៉េ និងបានលើកទឹកចិត្តឲ្យខិតខំប្រឹងប្រែងថែមទៀត ដើម្បីជំរុញការភ្ជាប់រវាងប្រជាជន និងប្រជាជន និងរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ។

កិច្ចប្រជុំកំពូលបានឯកភាពតាមសំណើរបស់សាធារណរដ្ឋកូរ៉េ ក្នុងការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ នៅឆ្នាំក្រោយ នៅសាធារណរដ្ឋកូរ៉េ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍ ៣០ឆ្នាំនៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សាធារណរដ្ឋកូរ៉េ។ កិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េ លើកទី១ នឹងត្រូវរៀបចំស្របគ្នាជាមួយកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍។

**កម្មវិធីអាហារការងារថ្ងៃត្រង់រៀបចំដោយ ឯកឧត្តម លី សៀនឡុង សម្រាប់ថ្នាក់ដឹកនាំអាស៊ាន**

ក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ាន ឯកឧត្តម **លី សៀនឡុង** បានរៀបចំអាហារថ្ងៃត្រង់ការងារក្រោមមូលបទ "ពាណិជ្ជកម្មសេរី និងសេដ្ឋកិច្ចពិភពលោក"។ អញ្ជើញចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់នេះរួមមាន ថ្នាក់ដឹកនាំអាស៊ានទាំងអស់ នាយករដ្ឋមន្ត្រីកាណាដា ដែលជាប្រធាន G7 នៅក្នុងឆ្នាំ២០១៨ ប្រធានាធិបតីឈីលី ដែលជាប្រធាន APEC នៅក្នុងឆ្នាំ២០១៨ និងអគ្គនាយកមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

កិច្ចពិភាក្សាផ្តោតជាសំខាន់ទៅលើសារៈសំខាន់នៃការធ្វើឲ្យប្រសើរឡើងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ក៏ដូចជាប្រព័ន្ធហិរញ្ញវត្ថុ និងអភិបាលកិច្ច ដើម្បីធានាបានសាកលភាវូបនីយកម្មផ្តល់ប្រយោជន៍ដល់ប្រជាជនប្រកបដោយបរិយាប័ន្នថែមទៀត។ ថ្នាក់ដឹកនាំបានទទួលស្គាល់អំពីសារៈសំខាន់នៃការផ្តល់ការគាំទ្រសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលនឹងត្រូវធ្វើសមាហរណកម្មទៅក្នុងខ្សែសង្វាក់ផលិតកម្មពិភពលោក ដោយអនុលោមតាមបរិយាកាសពាណិជ្ជកម្មពិភពលោកដែលបើកចំហរ ផ្តល់ផលប្រយោជន៍ទៅវិញទៅមក ផ្អែកលើច្បាប់ និងមានបរិយាប័ន្នភាព។ ថ្នាក់ដឹកនាំកត់សម្គាល់ដោយរីករាយនូវការខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឲ្យកាន់តែស៊ីជម្រៅ តាមរយៈគំនិតផ្តួចផ្តើមនានាដូចជា បណ្តាញទីក្រុងឆ្លាតអាស៊ាន ច្រកចេញ-ចូលតែមួយរបស់អាស៊ាន និងកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មអេឡិចត្រូនិច។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសំដែងការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មរបស់ដៃគូអាស៊ាន ក្នុងការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិត ដើម្បីចាប់យក

ឱកាសឌីជីថលសម្រាប់ ជំរុញការអនុវត្តរបៀបវារៈសហគមន៍សេដ្ឋកិច្ចអាស៊ាន និងពង្រឹងការប្រកួតប្រជែងរបស់អាស៊ានរយៈពេលវែង។

**កិច្ចប្រជុំកំពូលអាស៊ាន-រុស្ស៊ី លើកទី៣**

ថ្នាក់ដឹកនាំអាស៊ានបានវាយតម្លៃខ្ពស់ចំពោះការបន្តគាំទ្ររបស់រុស្ស៊ីសម្រាប់មជ្ឈភាពរបស់អាស៊ាន និងការចូលរួមយ៉ាងសកម្មរបស់រុស្ស៊ីនៅក្នុងយន្តការនានាដែលដឹកនាំដោយអាស៊ាន។

កិច្ចប្រជុំកំពូលបានឯកភាពក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លើយតបទៅនឹងការប្រឈមផ្នែកសន្តិសុខប្រពៃណី និងមិនប្រពៃណី ដូចជា អំពើភេរវកម្មអន្តរជាតិ ឧក្រិដ្ឋកម្មឆ្លងដែន ការគំរាមកំហែង និងការប្រឈមនានាដែលកំពុងកើតចេញមកពីការប្រើប្រាស់ ICTs។

ថ្នាក់ដឹកនាំ ក៏បានធ្វើជាសាក្សីការចុះហត្ថលេខាដោយអគ្គលេខាធិការអាស៊ាន និងប្រធានគណៈកម្មការសេដ្ឋកិច្ចអឺរ៉ាស៊ី (ECC) លើអនុស្សរណៈនៃការយោគយល់គ្នា រវាងអាស៊ាន និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ាស៊ី (ECC) ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។

**សម្ដេចតេជោនាយករដ្ឋមន្ត្រី** រួមជាមួយ ថ្នាក់ដឹកនាំអាស៊ានទាំងអស់ បានឯកភាពក្នុងការតម្លើងទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-រុស្ស៊ី ពីភាពជាដៃគូគ្រប់ជ្រុងជ្រោយ ទៅជាភាពជាដៃគូយុទ្ធសាស្ត្រ និងបានអនុម័តសេចក្ដីថ្លែងការណ៍រួមរបស់កិច្ចប្រជុំកំពូលអាស៊ាន-សហព័ន្ធរុស្ស៊ីលើកទី៣ ស្ដីពីភាពជាដៃគូយុទ្ធសាស្ត្រ។

**កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន លើកទី២១**

កិច្ចប្រជុំកំពូលបានកោតសរសើរនូវវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តផែនទីចង្អុលផ្លូវនៃកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រសេដ្ឋកិច្ច ១០ឆ្នាំ អាស៊ាន-ជប៉ុន នៅក្នុងវិស័យផ្សេងៗរួមមាន សកម្មភាពលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍសហគ្រាសមីក្រូធុនតូច និងមធ្យម ហេដ្ឋារចនាសម្ព័ន្ធ នវានុវត្តន៍ និងបច្ចេកវិទ្យា។

**សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានសំដែងការកោតសរសើរដល់ការរួមចំណែកដ៏សំខាន់របស់ជប៉ុនក្នុងការកសាងសហគមន៍អាស៊ាន និងសមាហរណកម្មអាស៊ាន តាមរយៈមូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន។ **សម្ដេចតេជោ**បានអះអាងជាថ្មីពីកិច្ចប្រឹងប្រែងរបស់ជប៉ុនក្នុងការជួយប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ក្នុងការបំពេញគម្លាតអភិវឌ្ឍន៍នៅក្នុងតំបន់ ជាពិសេសតាមរយៈការគាំទ្រការបណ្ដុះបណ្ដាលធនធានមនុស្ស និងពង្រឹងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។

កិច្ចប្រជុំកំពូលបានអនុម័តសេចក្ដីថ្លែងការណ៍រួមកិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន លើកទី២១ ដើម្បីប្រារព្ធខួបលើកទី៤៥ នៃមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ាន- ជប៉ុន។

**កិច្ចប្រជុំថ្នាក់ដឹកនាំនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) លើកទី២**

ថ្នាក់ដឹកនាំបានស្វាគមន៍វឌ្ឍនភាពប្រកបដោយខ្លឹមសារដែលសម្រេចបាននៅក្នុងការចរចារ RCEP នៅក្នុងឆ្នាំ២០១៨ និងការរីកចំរើនទៅកាន់ដំណាក់កាលចុងក្រោយនៃការចរចា។ ថ្នាក់ដឹកនាំបានប្ដេជ្ញាចិត្តសម្រេចឲ្យបាន RCEP មួយ ដែលទំនើប គ្រប់ជ្រុងជ្រោយ គុណភាពខ្ពស់ និងមានផលប្រយោជន៍ទៅវិញទៅមក នៅក្នុងឆ្នាំ២០១៩។

**កិច្ចប្រជុំកំពូលក្រៅផ្លូវការអាស៊ាន-ឥណ្ឌា អមដោយអាហារពេលព្រឹក**

ថ្នាក់ដឹកនាំបានអះអាងសារជាថ្មីពីការប្ដេជ្ញាចិត្តក្នុងការធ្វើឲ្យស៊ីជម្រៅ និងរឹងមាំ ភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ឥណ្ឌា ដើម្បីផលប្រយោជន៍ទៅវិញទៅមក គ្រប់ដណ្ដប់លើសសរស្ដម្ភ នយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គមវប្បធម៌។

ថ្លែងនៅក្នុងកិច្ចប្រជុំកំពូល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្នើឲ្យខិតខំរួមគ្នាបន្ថែមទៀតក្នុងការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឲ្យបានកាន់តែច្រើន និងទូលំទំលាយ តាមរយៈការពង្រឹងនិងពង្រីកសកម្មភាពធុរកិច្ច ការវិនិយោគ និងពាណិជ្ជកម្ម។

**សម្តេចតេជោ** ក៏បានស្វាគមន៍ការកំណត់យកឆ្នាំ២០១៩ ជាឆ្នាំទេសចរណ៍អាស៊ាន-ឥណ្ឌា និងសង្ឃឹមថា នឹងមានសកម្មភាព និងគម្រោងនានា ដើម្បីពង្រឹងនូវការផ្លាស់ប្តូរប្រជាជន និងប្រជាជន ក៏ដូចជាលំហូរទេសចរនៃតំបន់ទាំងពីរ។

**កិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិក លើកទី៦**

ថ្នាក់ដឹកនាំបានកត់សម្គាល់ថា សហរដ្ឋអាមេរិកគឺជាដៃគូពាណិជ្ជកម្មធំបំផុតទី៣របស់អាស៊ាន។ នៅក្នុងទិដ្ឋភាពនេះ ថ្នាក់ដឹកនាំបានរួមគ្នាតាំងចិត្តរក្សាទីផ្សារបើកចំហរ និងបរិយាប័ន្ន រក្សាតម្លាភាព និងបរិយាកាសធុរកិច្ចពិភពលោកដែលអាចព្យាករណ៍បាន។ ថ្នាក់ដឹកនាំបានកោតសរសើរការគាំទ្ររបស់អាមេរិកដល់សមាហរណកម្មសេដ្ឋកិច្ចរបស់អាស៊ាន និងកិច្ចប្រឹងប្រែងជំរុញការកសាងសហគមន៍ តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាច្រើន។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ការកោតសរសើររបស់កម្ពុជា ចំពោះវឌ្ឍនភាពដ៏ប្រសើរក្នុងការអនុវត្តការរៀបចំក្របខ័ណ្ឌការងារវិនិយោគ និងពាណិជ្ជកម្ម និងគំនិតផ្តួចផ្តើមផែនការនៃការពង្រីកការចូលរួមក្នុងផ្នែកសេដ្ឋកិច្ចអាស៊ាន និងសហរដ្ឋអាមេរិក។

ចំពោះការគាំទ្ររបស់សហរដ្ឋអាមេរិកក្នុងការកសាងធនធានមនុស្ស និងវិស័យអប់រំនៅតំបន់អាស៊ាន **សម្តេចតេជោ** បានស្នើឲ្យអាមេរិកបន្តផ្តល់ឱកាសអាហារូបករណ៍បន្ថែមទៀតដល់យុវជនអាស៊ាន និងជាពិសេសយុវជនកម្ពុជា ដើម្បីបានទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សាបន្ថែមទៀត។

**កិច្ចប្រជុំកំពូលអាស៊ានបូកបី លើកទី២១**

ថ្នាក់ដឹកនាំបានទទួលស្គាល់អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបី ក្នុងការថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងអាស៊ីបូព៌ា។ ថ្នាក់ដឹកនាំ ក៏បានអះអាងសារជាថ្មីអំពីការគាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគីឈរលើគោលការណ៍ច្បាប់ ដែលបើកចំហរ និងមានបរិយាប័ន្ន នៅចំពោះមុខបរិយាកាសពាណិជ្ជកម្មដែលមិនប្រកដប្រជា។ ថ្នាក់ដឹកនាំក៏បានពិភាក្សាគំនិតផ្តួចផ្តើមថ្មីៗជាច្រើនដើម្បីជម្រុញកិច្ចសហប្រតិបត្តិការអាស៊ានបូកបី លើគ្រប់វិស័យ ឆ្ពោះទៅកសាងសហគមន៍អាស៊ីបូព៌ា។

**សម្តេចតេជោ** បានចែករំលែកទស្សនទានអំពីសារៈសំខាន់នៃការធ្វើឲ្យប្រសើរឡើងគុណភាពជីវិត និងសុខុមាលភាពប្រជាជននៅក្នុងប្រទេសអាស៊ានបូកបី តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងអន់គុណភាព។ កិច្ចប្រជុំកំពូលបានអនុម័តសេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានបូកបី ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងភាពស៊ាំទៅនឹងឱសថអង់ទីប៊ីយោទិក ។

**កិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី១៣ (ពេញអង្គ)**

ថ្នាក់ដឹកនាំបានអះអាងសារជាថ្មី ពីការប្តេជ្ញាក្នុងការពង្រឹងថែមទៀតវេទិកាកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដែលជាវេទិកាថ្នាក់ដឹកនាំកំពូល សម្រាប់កិច្ចសន្ទនាលើបញ្ហាយុទ្ធសាស្ត្រទូលំទូលាយ នយោបាយ និងសេដ្ឋកិច្ច ដែលជាផលប្រយោជន៍ និងក្តីកង្វល់រួម ក្នុងគោលបំណងលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពសេដ្ឋកិច្ចនៅក្នុងតំបន់។

ថ្នាក់ដឹកនាំក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗនានារួមមាន វិស័យបរិស្ថាន និងថាមពល អប់រំ ហិរញ្ញវត្ថុ សុខាភិបាល ការគ្រប់គ្រងគ្រោះមហន្តរាយ ការតភ្ជាប់តំបន់ ពាណិជ្ជកម្ម និងសេដ្ឋកិច្ច សន្តិសុខស្បៀង ព័ត៌មានវិទ្យា និងបច្ចេកវិទ្យាទូរគមនាគមន៍។ ដើម្បីសម្រេចគោលដៅនេះ ថ្នាក់

ដឹកនាំបានអនុម័តសេចក្តីថ្លែងការណ៍ចំនួន៥ ដោយផ្តោតលើកាកសំណល់ក្នុងសមុទ្រ ប្រយុទ្ធប្រឆាំងភេរវកម្ម ICT និងសេដ្ឋកិច្ចឌីជីថល ទីក្រុងឆ្លាត និងសុវត្ថិភាពនុយក្លេអ៊ែរ។

ថ្នាក់ដឹកនាំ ក៏បានផ្លាស់ប្តូរទស្សនលើបញ្ហាតំបន់ និងពិភពលោកផងដែររួមមាន បញ្ហាឧបទ្វីបកូរ៉េ រដ្ឋរ៉ាក់ឃីន បញ្ហាសមុទ្រចិនខាងត្បូង ការប្រែប្រួលអាកាសធាតុ សន្តិសុខប្រព័ន្ធអ៊ីនធឺណែត អំពើភេរវកម្ម និងអំពើហឹង្សាជ្រុលនិយម និងប្រព័ន្ធពាណិជ្ជកម្មពហុភាគី៕

ថ្ងៃសុក្រ ៩កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨